ASIAN DEVELOPMENT BANK
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel +63 2 632 4444
Fax +63 2 636 2444

www.adb.org

NEWS RELEASE

# ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់កម្ចីសម្បទានបង្កើនគុណភាព និងលទ្ធភាព ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅប្រទេសកម្ពុជា

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា (២៦ កញ្ញា ២០១៤)** - ធនាគារអភិវឌ្ឍន៍អាស៊ី (ហៅកាត់ថា ADB) នឹងផ្តល់កម្ចីសម្បទានចំនួន ៣០ លានដុល្លារ សម្រាប់កម្មវិធីមួយ ដែលនឹងអនុវត្តនៅទូទាំងប្រទេស ដើម្បី បង្កើនគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៅក្នុងប្រទេសកម្ពុជា ដែលនឹងនាំឱ្យមានការបង្កើតឱកាសការងារបន្ថែមទៀតដល់ស្ត្រី និងជនក្រីក្រ។

លោក Norman LaRocque អ្នកឯកទេសផ្នែកអប់រំរបស់ ADB និយាយថា "ប្រព័ន្ធ TVETរបស់កម្ពុជានៅមានភាពក្មេងខ្ចី ហើយត្រូវការកំណែទម្រង់ និងការវិនិយោគ បន្ថែមទៀត ដើម្បីបំពេញចំណុចខ្វះខាតខាងលទ្ធភាពទទួលបាន គុណភាព និងសមត្ថភាពស្ថាប័ន សំដៅចូលរួមអភិវឌ្ឍកម្លាំងពលកម្មជំនាញប្រកបដោយនិរន្តរភាព។ កម្មវិធីនេះនឹងធ្វើការ កែលំអប្រព័ន្ធដែលមានស្រាប់ ដើម្បីធ្វើឱ្យប្រព័ន្ធនេះកាន់តែឆ្លើយតបចំពោះតម្រូវការទីផ្សារការងារ និងផ្តល់ឱកាសឱ្យក្រុមដែលជួបប្រទះការលំបាកទទួលបានការបណ្តុះបណ្តាលតាមប្រព័ន្ធផ្លូវការ"។

គម្រោងនេះនឹងគាំទ្រការបង្កើតប្រព័ន្ធវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រ ផ្អែកទៅតាមសមត្ថភាព រួមនឹងការបង្កើតនូវមធ្យោបាយសិក្សាដែលមានលក្ខណៈបត់បែន និងផ្លាស់ប្តូររវាងកម្រិតគុណវឌ្ឍិ និងប្រភេទនៃការបណ្តុះបណ្តាលផ្សេងៗគ្នា។ កម្មវិធីនេះក៏នឹងដាក់ឱ្យអនុវត្តនូវប្រព័ន្ធធានាគុណភាពសម្រាប់ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើតកម្មវិធីហ្វឹកហ្វឺនសម្រាប់គ្រូអប់រំបណ្តុះ បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ដើម្បីឱ្យពួកគេទទួលបានបទពិសោធន៍ផ្នែកឧស្សាហកម្មផង ដែរ។ ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលមានសមាសភាពជាសមាគមឧស្សាហកម្ម និងនិយោជកធំៗ ក្នុង វិស័យអាទិភាពចំនួន ៤ ដូចជា សំណង់ ជួសជុលរថយន្ត ការងារអគ្គិសនី និងកម្មន្តសាល នឹងត្រូវបង្កើតឡើងដើម្បីជួយដល់ការអភិវឌ្ឍន៍មណ្ឌលធនធានជំនាញជាក់លាក់។

កម្មវិធីនេះមានដាក់បញ្ចូលនូវលក្ខណៈច្នៃប្រឌិតថ្មីជាច្រើនបន្ថែមពីលើគម្រោងដែលADB ធ្លាប់គាំទ្រនាពេលកន្លងមកក្នុងវិស័យអប់រំកម្រិតមូលដ្ឋាន និងវិស័យ អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ភាពច្នៃប្រឌិតថ្មីៗនោះ រួមមាន (i) ការបង្កើតនូវប្រព័ន្ធសម្រាប់ទទួលស្គាល់លើលទ្ធផលសិក្សាដែលបានបញ្ចប់តាមកម្រិតគុណវឌ្ឍិ (ii) យុទ្ធសាស្ត្រដើម្បីលើកកម្ពស់ការចូលរួមរបស់វិស័យឯក

ជន និងនិយោជក ក្នុងការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង (iii) ពង្រឹងការគ្រប់គ្រង ផ្អែកទៅតាមលទ្ធផលការងារជាក់ស្តែង ដើម្បីបង្កើនគណនេយ្យភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ ធនធានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

កម្មវិធីនេះនឹងផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកមកពីគ្រួសារក្រីក្រ ដែលត្រូវបានកំណត់ក្រោមកម្មវិធី ផ្តល់ការគាំទ្រដល់គ្រួសាររបស់រដ្ឋាភិបាល និងដល់អន្តេវាសិកដ្ឋានស្ត្រី។ ផែនការសកម្មភាពយេនឌ័រ ដែល កំណត់កូតាសម្រាប់ស្ត្រី ដែលត្រូវទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ចូលរួមក្នុងការបណ្តុះបណ្តាល ក៏នឹងជួយ បង្កើនចំនួនស្ត្រី ដែលចុះឈ្មោះចូលរៀន និងបន្តរៀនសូត្រក្នុងកម្មវិធីអប់រំបណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈតាមប្រព័ន្ធផ្លូវការផងដែរ។

ដើម្បីពង្រឹងការងារអភិបាលកិច្ច និងគ្រប់គ្រង នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នឹងទទួលបានការកសាងសមត្ថភាព ដូចជា ជំនាញរៀបចំផែនការថវិកា និងជំនាញផ្សេង ទៀត ជាដើម។ ជំនួយហិរញ្ញវត្ថុសម្រាប់ដំណើរការ ក៏នឹងត្រូវផ្តល់ផងដែរ ដើម្បីផ្តល់លទ្ធភាពឱ្យ មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងនេះ អាចផ្តល់នូវវគ្គសិក្សាក្នុងមុខជំនាញ សំណង់ ជួសជុលរថយន្ត បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងធុរកិច្ច ចាប់ពីកម្រិត ២ ដល់ កម្រិត ៤ ក្រោមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

ជំនួយរបស់ ADB បានពីមូលនិធអភិវឌ្ឍន៍អាស៊ី ដែលមានលក្ខណៈសម្បទាន ខណៈពេល ដែលរដ្ឋាភិបាលកម្ពុជានឹងចូលរួមបដិភាគជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ សរុបចំនួន ២,៦ លាន ដុល្លារ ដែលនាំឱ្យការវិនិយោគសរុបមានចំនួន ៣២,៦ លានដុល្លារ។ កម្មវិធីនេះនឹងដំណើរការរយៈ ពេល ៥ ឆ្នាំ ដែលត្រូវបានរំពឹងថានឹងបញ្ចប់នៅខែ ធ្នូ ឆ្នាំ ២០១៩។

មានមូលដ្ឋាននៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រ នៅអាស៊ី និងប៉ាស៊ីហ្វិក តាមរយៈកំណើនសេដ្ឋកិច្ចដើម្បីទាំងអស់គ្នា កំណើនដែលធានានិរន្តរភាពបរិស្ថាន និង សមាហរណកម្មតំបន់។ បង្កើតឡើងនៅក្នុងឆ្នាំ ១៩៦៦ ធនាគារនេះគឺជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ប្រទេស ដែលក្នុងនោះមាន ៤៨ ប្រទេស មកពីតំបន់នេះ។នៅក្នុងឆ្នាំ ២០១៣ ជំនួយដែលផ្តល់ ដោយធនាគារអភិវឌ្ឍន៍អាស៊ីសរុបមានចំនួន ២១ ពាន់លានដុល្លារ បូករួមទាំងសហប្រទានចំនួន ៦,៦ ពាន់លានដុល្លារផង៕